អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១១ ខែ តុលា ឆ្នាំ ២០១៨

# សេចក្តីជូនដំណឹង

## ព័ត៌មានស្តីពីការចូលរួមរបស់សាធារណជន និងអ្នកសារព័ត៌មាននៅក្នុងថ្ងៃប្រកាសសាលក្រម ក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា និងខៀវ សំផន នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) បានចេញដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រមនៅក្នុងសំណុំរឿង ០០២/០២ ដោយបានជូនដំណឹងដល់ភាគីនានាថា អនុលោមតាមវិធាន ១០២ (១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងនឹងប្រកាសសេចក្តីសំអាងហេតុ និងផ្នែកនៃ សេចក្តីសម្រេចនៃសាលក្រមក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជាង និងខៀវ សំផន ***នៅថ្ងៃសុក្រ ទី១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ នៅក្នុងសាលសវនាការធំនៃ អ.វ.ត.ក ចាប់ពីម៉ោង ០៩:៣០ នាទីព្រឹក***។

### ព័ត៌មានសម្រាប់អ្នកមកចូលរួម និងអ្នកសារព័ត៌មាន

សាលសវនាការមានកន្លែងអង្គុយចំនួន ៤៨០ កន្លែង ដែលនឹងត្រូវរៀបចំបែងចែកដូចតទៅៈ

### 1.ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២ និងតំណាងផ្លូវច្បាប់

កន្លែងអង្គុយចំនួន ១៤០ កន្លែង ត្រូវបានត្រៀមទុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ដែលនឹងសម្របសម្រួលដោយអង្គភាពគាំពារជនរងគ្រោះ និងអង្គការអន្តរការី និងតំណាងផ្លូវច្បាប់របស់ពួកគាត់។ ក្នុងថ្ងៃប្រកាសសាលក្រម កន្លែងអង្គុយណាដែលនៅទំនេរត្រឹមម៉ោង ៨ និង ៤៥ នាទី ព្រឹក នឹងត្រូវផ្តល់ជូនសាធារណជនទូទៅ។

### 2. តំណាងរាជរដ្ឋាភិបាល ភ្ញៀវអង្គទូត និងអ្នកស្រាវជ្រាវ

កន្លែងអង្គុយចំនួន ៨០ កន្លែង ត្រូវបានត្រៀមទុកសម្រាប់ភ្ញៀវតំណាងរាជរដ្ឋាភិបាល អង្គទូត និងអ្នកស្រាវជ្រាវ។ សូមចុះឈ្មោះកក់កន្លែងទុកជាមុនតាមរយៈសារអេឡិចត្រូនិក pas@eccc.gov.kh។ ការចុះឈ្មោះកក់កន្លែងទុកជាមុននឹងផុតកំណត់នៅវេលាម៉ោង ៤ រសៀល ថ្ងៃ សុក្រ ទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨។ នៅក្នុងថ្ងៃប្រកាសសាលក្រម

កន្លែងអង្គុយណាដែលនៅទំនេរត្រឹមម៉ោង ៨ និង ៤៥ នាទី ព្រឹក នឹងត្រូវផ្តល់ជូនសាធារណជនទូទៅ។

**3.តំណាងរបស់អង្គការមិនមែនរដ្ឋាភិបាល**

កន្លែងអង្គុយចំនួន ៤0 កន្លែង ត្រូវបានត្រៀមទុកសម្រាប់ឲ្យតំណាងរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលមានកម្មវិធីទាក់ទងនឹង អ ក។ សូមចុះឈ្មោះកក់កន្លែងទុកជាមុនតាមរយៈសារអេឡិចត្រូនិក.ត.វ.pas@eccc.gov.kh។ ការចុះឈ្មោះកក់កន្លែងទុកជាមុននឹងផុតកំណត់នៅវេលាម៉ោង ៤ រសៀល ថ្ងៃ សុក្រ ទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨។ ក្រោយផុតកំណត់រយៈពេលចុះឈ្មោះកក់កន្លែងទុកជាមុន និងអាស្រ័យលើចំនួនសរុបនៃអ្នកចុះឈ្មោះកក់កន្លែងទុកជាមុន អ.ក នឹងជូនដំណឹងអំពីចំនួនកន្លែងដែលបម្រុងទុក សម្រាប់អង្គការមិនមែនរដ្ឋាភិបាលនីមួយៗ។ ប្រសិនបើចំនួនអ្នក.ត.វ ចុះឈ្មោះកក់កន្លែងទុកជាមុន លើសពីចំនួនកន្លែងអង្គុយសរុបដែលត្រៀមបម្រុងទុក អក នឹងផ្តល់កន្លែង.ត.វ. អង្គុយដល់តំណាងអង្គការមិនមែនរដ្ឋាភិបាលនីមួយៗ ផ្អែកតាមអាទិភាពដូចខាងក្រោម៖

១បុគ្គលិកមកពីអង្គការអន្តរការី .

២បុគ្គលិកពាក់ព័ន្ធនឹងកម្មវិធីតាមដានតុលាការជាទៀងទាត់ .

៣អង្គការមិនមែនរដ្ឋាភិបាល ដែលមានវត្តមានទៀងទាត់នៅក្នុងសវនាក .ារកាលពីលើកមុនៗ។

៤ផ្សេងៗទៀត .

នៅក្នុងថ្ងៃប្រកាសសាលក្រម កន្លែងអង្គុយណាដែលនៅទំនេរត្រឹមម៉ោង ៨ និង ៤៥ នាទី ព្រឹក នឹងផ្តល់ជូនសាធារណជនទូទៅ។

**4. តំណាងសារព័ត៌មាន**

កន្លែងអង្គុយនៅក្នុងសាលសវនាការចំនួន ២0 កន្លែង នឹងបម្រុងទុកសម្រាប់តំណាងសារព័ត៌មាន ចំណែកសមាជិកអ្នកសារព័ត៌មានដែលនៅសេសសល់នឹងត្រូវបានផ្តល់កន្លែងអង្គុយនៅបន្ទប់សារព័ត៌មាន C105 នៅជាន់ផ្ទាល់ដីនៃអគារតុលាការ។ សូមចុះឈ្មោះកក់កន្លែងអង្គុយនៅក្នុងសាលសវនាការទុកជាមុនអ្នកតាមរយៈសារអេឡិចត្រូនិក pas@eccc.gov.kh។ ការចុះឈ្មោះកក់កន្លែងទុកជាមុននឹងផុតកំណត់នៅវេលាម៉ោង ៤ រសៀល ថ្ងៃ សុក្រ ទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨។

**5. សាធារណជនទូទៅ**

កន្លែងអង្គុយចំនួន ២០០ កន្លែង នឹងបម្រុងទុកសម្រាប់សាធារណជនទូទៅ ហើយនឹងផ្តល់ជូនសាធារណជនផ្អែកតាមគោលការណ៍មកមុន បានមុន។ ទ្វារច្រកចូលសម្រាប់ភ្ញៀវនឹងបើកនៅម៉ោង ៧ ព្រឹក។ អក ណែនាំឲ្យអ្នកចូល.ត.វ. រួមគួរតែមកដល់ច្រកត្រួតពិនិត្យសន្តិសុខឲ្យបានមុនដើម្បីទុកពេលវេលាគ្រប់គ្រាន់សម្រាប់

ការត្រួតពិនិត្យសន្តិសុខ និងការចែកប័ណ្ណចូលរួមសវនាការ។ អក នឹងបិទច្រកចូលទៅកាន់សាល.ត.វ.
សវនាការនៅម៉ោង ៩ និង ០០ នាទី ព្រឹក ឬ នៅពេលដែលសាលសវនាការមានមនុស្សអង្គុយពេញ។

សូមរំឭកថា ដើម្បីចូលក្នុងសាលសវនាការ អ្នកចូលរួមទាំងអស់ត្រូវតែបង្ហាញប័ណ្ណសម្គាល់ខ្លួន ដែលមានបិទរូប)
ឆ្នាំ នឹងមិនត្រូវបានអនុញ្ញាតឲ្យចូលរួម១៦ដល់សន្តិសុខនៅច្រកមាត់ទ្វារខាងក្រៅ។ អ្នកដែលមានអាយុក្រោម (ថត
 ឆ្នាំ អាចចូលបាន ១៨ ដល់ ១៦ ឡើយ ហើយអ្នកដែលមានអាយុចន្លោះពីលុះត្រាតែមានអាណាព្យាបាលមកជាមួយ។
សាធារណជនត្រូវតែរក្សាភាពថ្លៃថ្នូរ និងអាកប្បកិរិយាសមរម្យគ្រប់ពេលវេលា និងត្រូវមានសម្លៀកបំពាក់សមរម្យ។
មិនអនុញ្ញាតឲ្យយកទូរស័ព្ទដៃ កាបូបធំៗ អាហារ ឬ ភេសជ្ជៈ ចូលក្នុងសាលសវនាការឡើយ។
អគីឡូម៉ែត្ ១៦ ក មានទីតាំងនៅសង្កាត់ចោមចៅ ចម្ងាយ.ត.វ.រ ពីរាជធានីភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ ៤
ឆ្ពោះទៅកាន់ខេត្តព្រះសីហនុ។ សូមអញ្ជើញសាធារណជន និងអ្នកសារព័ត៌មានចូលតាមច្រកសម្រាប់ភ្ញៀវដែលស្ថិត
នៅផ្នែកខាងកើតនៃ អក មានទីធ្លាសម្រាប់ភ្ញៀវចតយានយន្ត។.ត.វ.ក។ អ.ត.វ.

ការចុះឈ្មោះសុំប័ណ្ណព័ត៌មានសម្រាប់អ្នកសារព័ត៌មានអ្នកសារព័ត៌មានដែលមានបំណងចូលរួមតាមដានដំណើរការ
សវនាការនៅ អត្រូវតែមានប័ណ្ណសម្រាប់អ្នកសារព័ត៌មាន និងត្រូវចុះ ២០១៨ ខែ វិច្ឆិកា ឆ្នាំ ១៦ ក នៅថ្ងៃទី.ត.វ.
ឈ្មោះជាមុន។ សូមអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោមដើម្បីសុំប័ណ្ណព័ត៌មាន៖
ក អ្នកសារព័ត៌មានដែលមិនទាន់មានប័ណ្ណព័ត៌មានដែលចេញដោយ (អក ត្រូវបំពេញទម្រង់បែបបទសុំប័ណ្ណ.ត.វ.
 សារព័ត៌មានដោយមានចុះហត្ថលេខា ភ្ជាប់រូបថតទម្រង់jpg មួយសន្លឹក និងច្បាប់ចម្លងលិខិតឆ្លងដែនមួយច្បាប់ ផ្ញើ
មកជាមួយសំណើសុំចុះឈ្មោះដើម្បីចូលរួមតាមដានការប្រកាសសាលក្រមនៅថ្ងៃទី ១៦ ខែ វិច្ឆិកា តាមរយៈសារអេ
ឡិចត្រូនិក PAS@ECCC.GOV.KH។
ក ត្រូវចុះឈ្មោះ.ត.វ.អ្នកសារព័ត៌មានដែលកំពុងកាន់ប័ណ្ណព័ត៌មានដែលនៅមានសុពលភាពជាផ្លូវការរបស់ អ (ខ
ខែវិច្ឆិកានៅផ្នែកកិច្ចការសាធារណៈតាមរយៈការផ្ញើសារអេឡិចត្រូនិកទៅកាន់ ១៦ដើម្បីចូលរួមតាមដាននៅថ្ងៃទី
PAS@ECCC.GOV.KH។
គក ប៉ុន្តែផុតកំណត់ ត្រូវបំពេញទម្រង់បែបបទសុំប័.ត.វ.អ្នកសារព័ត៌មានដែលមានប័ណ្ណព័ត៌មានជាផ្លូវការរបស់ អ (
ណ្ណព័ត៌មានសារជាថ្មី ដោយមានចុះហត្ថលេខា ផ្ញើមកជាមួយនឹងសំណើសុំចុះឈ្មោះដើម្បីចូលរួមតាមដាននៅថ្ងៃទី
ខែ វិច្ឆិកា តាមរយៈសារអេឡិចត្រូនិ ១៦ក PAS@ECCC.GOV.KH។ សូមកុំភ្លេចបញ្ជាក់លេខប័ណ្ណចាស់ដែលផុត
កំណត់ផង។
ទម្រង់បែបបទសម្រាប់សុំប័ណ្ណព័ត៌មាន អាចទាញយកបានពីគេហទំព័ររបស់ អក:.ត.វ.
http://www.eccc.gov.kh/sites/default/files/ECCC_Accreditation_Media_AppÉ

ខែ វិច្ឆិកា  ៩ ថ្ងៃផុតកំណត់ឈប់ទទួលការចុះឈ្មោះរបស់អ្នកសារព័ត៌មាន និងសំណើសុំប័ណ្ណព័ត៌មាន៖ ថ្ងៃ សុក្រ ទី ២០១ ឆ្នាំ៨ វេលាម៉ោង ៤ រសៀល។

**កន្លែងអង្គុយក្នុងសាលសវនាការដែលត្រៀមបម្រុងសម្រាប់អ្នកសារព័ត៌មាន**

កន្លែងអង្គុយក្នុងសាលសវនាការដែលត្រៀមបម្រុងសម្រាប់អ្នកសារព័ត៌មាន

អ្នកសារព័ត៌មានត្រូវតែមកដល់កន្លែងអង្គុយរបស់ខ្លួនឲ្យបាន ៣០ នាទី មុនពេលបើកសវនាការ។ ពុំអនុញ្ញាតឲ្យយកម៉ាស៊ីនថតរូប កុំព្យូទ័រយួរដៃ ទូរស័ព្ទដៃ ឬ ឧបករណ៍ថតសំឡេងនានា ចូលក្នុងសាលសវនាការនោះទេ។

**ការថតរូបភាព**

ផ្នែកកិច្ចការសាធារណៈនៃ អក នឹងផ្ដល់រូបភាពដែលមានគុណភាពច្បាស់ នៅពេលចាប់ផ្ដើមសវនាការ។.ត.វ.

**ការផ្សាយរូបភាពវីដេអូ និងសំឡេង**

ការផ្សាយសំឡេងអំពីដំណើរការសវនាការ នឹងត្រូវបានផ្ដល់ជូនអ្នកសារព័ត៌មានតាមប្រព័ន្ធ PHONO/XLR។ អ្នកសារព័ត៌មានអាចថតការផ្សាយសំឡេងនេះបាននៅក្នុងបន្ទប់តាមដានព័ត៌មាន )C105) ដោយប្រើឧបករណ៍ភ្ជាប់មួយក្នុងចំណោមឧបករណ៍ភ្ជាប់ចំនួន ៤៨ សម្រាប់ភាសានីមួយៗ ខ្មែរ អង់គ្លេស និង ១៦ មានឧបករណ៍ភ្ជាប់ចំនួន) ។ ការតភ្ជាប់ពីម៉ាស៊ីនថតសំឡេងមួយទៅម៉ាស៊ីនថតសំឡេងម(បារាំង ួយទៀត អាចធ្វើទៅបានប្រសិនបើអ្នកសារព័ត៌មានមានខ្សែសម្រាប់តភ្ជាប់។ ពុំអនុញ្ញាតឲ្យថតសំឡេងនៅក្នុងសាលសវនាការឡើយ។

ការផ្សាយរូបភាពវីដេអូអំពីដំណើរការសវនាការ នឹងត្រូវបានផ្ដល់ជូនតាមប្រព័ន្ធ BNC (PAL signal)។ អ្នកសារព័ត៌មានអាចថតរូបភាពវីដេអូ នៅក្នុងបន្ទប់តាមដានព័ត៌មាន )C105) ដោយប្រើប្រាស់ឧបករណ៍ភ្ជាប់មួយក្នុងចំណោមឧបករណ៍ភ្ជាប់ចំនួន ៣០ ដែលមាននៅទីនោះ។ ការតភ្ជាប់ពីម៉ាស៊ីនថតរូបភាពវីដេអូមួយទៅម៉ាស៊ីនថតរូបភាពវីដេអូមួយទៀតអាចធ្វើទៅបានប្រសិនបើអ្នកសារព័ត៌មានមានខ្សែសម្រាប់តភ្ជាប់។ ពុំអនុញ្ញាតឲ្យថតរូបភាពវីដេអូនៅក្នុងសាលសវនាការឡើយ។

ការដំឡើងឧបករណ៍សារព័ត៌មាន និងការកក់ទុកកន្លែងជាមុននៅបន្ទប់សារព័ត៌មាន C105

អ្នកសារព័ត៌មាន ដែលមានបំណងចង់ដំឡើងឧបករណ៍ជាមុន និងកក់ទុកកន្លែងជាមុននៅក្នុងបន្ទប់សារព័ត៌មាន អាចមកទស្សនា អ រសៀល។ ៤ ព្រឹក ដល់ម៉ោង ៩ ខែ វិច្ឆិកា ចន្លោះពីម៉ោង ១៤ ក នៅថ្ងៃ ពុធ ទី.ត.វ.

**បណ្ណព័ត៌មាន**

អ្នកសារព័ត៌មានអាចមកយកបណ្ណសារព័ត៌មាននៅ អ.វ.ត.ក នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ចន្លោះពីម៉ោង ៩ ព្រឹក ដល់ម៉ោង ៤ រសៀល ឬនៅច្រកទ្វារចូលសម្រាប់អ្នកសារព័ត៌មាននៅព្រឹកថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ តែម្តង។


សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក **នេត្រ ភក្ត្រា**

ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យនៃសាលាក្តីខ្មែរក្រហម

ទូរស័ព្ទ៖ +៨៥៥ ៩៨៨ ១២ (0) ១៥៦

អ៊ីមែល៖ neth.phektra@eccc.gov.kh